# ធ្វើការសិក្សាជ្រើសរើសគ្រឿងសម្អាងដែលកាន់តែមានសុវត្ថិភាព។

DEPARTMENT OF
ECOLOGY
State of Washington

**ECY** 24-04-061KM
ខែកុម្ភៈ 2025



ស្វែងយល់ពីរបៀបដែល
**អ្នក**
អាចរកផលិតផលដ៏កាន់តែ
មានសុវត្ថិភាព

# គ្រឿងសម្អាងដ៏កាន់តែមានសុវត្ថិភាពកំពុងតែមកកាន់ហាង និងហាងកែសម្ផស្សនៅក្បែរអ្នកហើយ។

គ្រឿងសម្អាងគឺលើសពីគ្រឿងតុបតែងខ្លួនទៅទៀត—រួមបញ្ចូលផលិតផលថែទាំខ្លួនភាគច្រើន ដូចជាសាប៊ូកក់សក់ ផលិតផលបំបាត់ក្លិនក្លៀក និងឡេ។ សារធាតុគីមីនៃគ្រឿងសម្អាងខ្លះផ្សារភ្ជាប់ទៅនឹងផលប៉ះពាល់សុខភាពដ៏គ្រោះថ្នាក់ ដូចជាផលប៉ះពាល់ដែលបានបង្ហាញនៅទីនេះ។ នៅរដ្ឋ Washington យើងកំពុងរឹតបន្តឹងលើការប្រើប្រាស់សារធាតុគីមីទាំងនេះនៅក្នុងគ្រឿងសម្អាង ដូច្នេះផលិតផលដែលអ្នកប្រើជារៀងរាល់ថ្ងៃកាន់តែមានសុវត្ថិភាពឡើង។







| សារធាតុគីមី | ផាឡាត | PFAS | ផម៉ាលដេអ៊ីតមេទីឡែនគ្លីកុល |
|---|---|---|---|
| មុខងារ | • សារធាតុបង្កើនភាពបត់បែន<br>• សារធាតុរំលាយ<br>• សារធាតុក្រអូប<br>• សារធាតុការពារពណ៌កុំឲ្យប្រតាក | មុខងារនានា រួមមាន៖<br>• សាប៊ូអប់បន្ទន់សក់ និងស្បែក<br>• ប៉ះពាល់ដល់វាយនភាព និងភាពរឹង ឬទន់របស់ផលិតផល | • សារធាតុជួយរក្សាឲ្យទុកបានយូរ<br>• ការធ្វើឲ្យសក់ត្រង់<br>• ការគ្រឿងសម្អាង |
| កង្វល់សុខភាព | អាចបង្អាក់ដល់អ័រម៉ូន និងបង្កគ្រោះថ្នាក់ដល់ការបន្តពូជ និងការលូតលាស់។ ពុលដល់ជីវិតសត្វក្នុងទឹក។ | អាច បង្កគ្រោះថ្នាក់ដល់ការបន្តពូជ និងការលូតលាស់ ជំងឺមហារីក ពុលដល់ក្រពេញទីរ៉ូអ៊ីត និងការឆ្លើយតបប្រព័ន្ធភាពស៊ាំថយចុះ។ | ធ្វើឲ្យរោលរាលក្រហាយដល់ស្បែក ភ្នែក និងប្រព័ន្ធដង្ហើម។ អាចបង្កការឆ្លើយតបនឹងប្រតិកម្មអាលែកហ្ស៊ីលើស្បែក ជំងឺហឺត ការខូចខាតដល់សួត និងជំងឺមហារីក។ |
| កន្លែងដែលវាអាចនឹងត្រូវបានរកឃើញ | ថ្នាំលាបក្រចក ស្ព្រាយបាញ់សក់ ឡេលាបក្រោយកោររោម ផលិតផលលាងសម្អាត និងសាប៊ូកក់សក់។ | គ្រឿងតុបតែងខ្លួន ស្ព្រាយបាញ់សក់ ឡេ សាប៊ូកក់សក់ ក្រែម និងម្សៅ។ | ផលិតផលធ្វើឲ្យសក់ត្រង់ ផលិតផលថែទាំសក់ ផលិតផលថែទាំស្បែក គ្រឿងតុបតែងខ្លួន និងការសម្រាប់បិទរោមភ្នែក |

ព័ត៌មាននេះត្រូវបានចងក្រងឡើងពីការសិក្សាដែលមានជាសាធារណៈអំពីគ្រឿងផ្សំជាសារធាតុគីមីដែលរកឃើញនៅក្នុងប្រភេទគ្រឿងសម្អាងមួយចំនួន។ វាមិនអស់នោះទេ ហើយវាមិនចាំបាច់ត្រូវអនុវត្តលើផលិតផលទាំងអស់នៅក្នុងប្រភេទមួយនោះដែរ។ អ្នកអាចនឹងត្រូវការព័ត៌មានដែលជាក់លាក់ចំពោះផលិតផលបន្ថែមទៀត ឬព័ត៌មានមកពីប្រភពដទៃទៀតដើម្បីជួយធ្វើការសម្រេចចិត្តផ្ទាល់ខ្លួន ឬបែបអាជីព។






| បារ៉ែត | ទ្រីក្លូសាន | m និង o ផេនីលឡែនេដ្យាមីន | សំណ |
|---|---|---|---|
| • សារធាតុជួយរក្សាឲ្យទុកបានយូរ<br>• សារធាតុបន្សស្បែក | សារធាតុជួយរក្សាឲ្យទុកបានយូរ | ជួយឲ្យសម្រេចបាននូវពណ៌ដែលចង់បាននៅក្នុងថ្នាំលាបសក់ | ភាពមិនសុទ្ធ ឬសារធាតុកខ្វក់ |
| ពុលដល់ខួរក្បាល និងប្រព័ន្ធប្រសាទ។ អាចធ្វើឲ្យខូចតម្រងនោម និងថ្លើម។ អាចបង្កប្រតិកម្មអាលែកហ្ស៊ីលើស្បែក។ | អាចបង្អាក់ដល់អ័រម៉ូន បង្កគ្រោះថ្នាក់ដល់ការលូតលាស់របស់កុមារ និងបង្កើត ភាពស៊ាំនឹងថ្នាំផ្សះ។ ពុលដល់ជីវិតសត្វក្នុងទឹក។ | អាចបង្កជំងឺមហារីក ការពុលដល់សរីរាង្គ និងប្រតិកម្មអាលែកហ្ស៊ីស្បែក។ ពុលដល់ជីវិតសត្វក្នុងទឹក។ | អាចបង្កជំងឺមហារីក គ្រោះថ្នាក់ដល់ការបន្តពូជ និងបង្កគ្រោះថ្នាក់ដល់ការលូតលាស់ខួរក្បាលរបស់កុមារ។ ពុលដល់ជីវិតសត្វក្នុងទឹក។ |
| ផលិតផលបន្សស្បែក ផលិតផលបំបាត់ស្នាមអុជខ្មៅ ឬស្នាមមិនស្អាត គ្រឿងសម្អាងនៅតំបន់ភ្នែក។ | ផលិតផលថែទាំស្បែក ទឹកអប់ គ្រឿងតុបតែង ផលិតផលថែរក្សាសក់ និងផលិតផលសម្រាប់ជម្រុះរោម។ | ថ្នាំលាបសក់ | ផលិតផលលាបត្របកភ្នែក ផលិតផលគូសរង្វង់ភ្នែក ម្សៅផាត់ថ្ពាល់ឲ្យក្រហម ក្រែមលាបមាត់ ម៉ាស ដឹតដូ។ |

# កាត់បន្ថយការប៉ះពាល់របស់អ្នកទៅនឹងសារធាតុគីមីពុល នៅក្នុងគ្រឿងសម្អាង។

**ទិញគ្រឿងសម្អាងនៅក្នុងរដ្ឋ Washington។** Toxic-Free Cosmetics Act (ច្បាប់ស្ដីពីគ្រឿងសម្អាងគ្មានជាតិពុល, TFCA) បញ្ឈប់សារធាតុគីមីដ៏គ្រោះថ្នាក់ជាច្រើនមិនឲ្យប្រើនៅក្នុងគ្រឿងសម្អាងដែលត្រូវបានលក់ ឬចែកចាយ នៅក្នុងរដ្ឋ Washington។

**រកមើលវិញ្ញាបនប័ត្រភាគីទីបី** ដូចជា Cradle to Cradle (វដ្ដជីវិត) ឬ EPA Safer Choice (ជម្រើសកាន់តែមានសុវត្ថិភាពរបស់ EPA)។ វិញ្ញាបនប័ត្រមានន័យថាអ្នកជំនាញបានត្រួតពិនិត្យគ្រឿងផ្សំឡើងវិញរួចហើយ។

**សួរអ្នកលក់រាយ និងអ្នកធ្វើម៉ូតអំពីផលិតផលមានសុវត្ថិភាព ដែលអនុលោមតាម TFCA។**



ដើម្បីស្នើសុំការសម្របសម្រួលពី ADA សូមទាក់ទងផ្នែកអេកូឡូស៊ីតាមទូរសព្ទលេខ 360-407-6700 ឬអ៊ីមែលតាម hwtrpubs@ecy.wa.gov ឬចូលទៅកាន់គេហទំព័រ ecology.wa.gov/accessibility។ សម្រាប់សេវាកម្មបញ្ជូនបន្ត ឬ TTY សូមហៅទៅលេខ 711 ឬលេខ 877-833-6341។

ស្កេននៅទីនេះ ដើម្បីស្វែងយល់បន្ថែម។

ecology.wa.gov/tfca